## ០១
### ប្រាក់ឈ្នួល និងការកាត់ប្រាក់ឈ្នួល

- ប្រាក់ឈ្នួលត្រូវតែបើករៀងរាល់មួយខែម្តងដោយផ្ទេរតាមរយៈធនាគារ/បើកតាមប្រព័ន្ធអេឡិកត្រូនិច។
- បើមានការបង់ប្រាក់តាមទិន្នផលនេសាទគួរតែត្រូវបើករៀងរាល់បីខែម្តង។
- ប្រាក់ឈ្នួលអប្បបរិមានៅប្រទេសថៃ (ឆ្នាំ២០២២) គឺមានចន្លោះពី៣២៨បាតទៅ៣៥៤បាតក្នុងមួយថ្ងៃ អាស្រ័យតាមខេត្តនិមួយៗ។
- ពលករត្រូវតែទទួលបានប្រាក់ឈ្នួលយ៉ាងតិចត្រឹមប្រាក់ឈ្នួលអប្បបរិមា។






## ០២
### ថេរៈវេលាធ្វើការងារ និងឈប់សម្រាក

**ផ្នែកកែច្នៃអាហារសមុទ្រ**

- ៨ម៉ោងក្នុងមួយថ្ងៃ
- ៦ថ្ងៃក្នុងមួយសប្តាហ៍
- យ៉ាងតិចទទួលបានការសម្រាក១ម៉ោងក្រោយធ្វើការ៥ម៉ោងជាប់គ្នា

ការធ្វើការបន្ថែមម៉ោងគឺជាការងារស្ម័គ្រចិត្ត។ ការបន្ថែមម៉ោង និងធ្វើការក្នុងថ្ងៃឈប់សម្រាកមិនត្រូវលើសពី៣៦ម៉ោងក្នុង១សប្តាហ៍។

**ផ្នែកនេសាទ**

- រយៈពេលសម្រាកចំនួន១០ម៉ោងត្រូវផ្តល់ឱ្យក្នុងរយៈពេលបំពេញការងារ២៤ម៉ោង (ថេរៈវេលាធ្វើការច្រើនបំផុតត្រឹម១៤ម៉ោង៖គ្មានការបន្ថែមម៉ោងក្នុងផ្នែកនេះទេ)
- ទទួលបានការសម្រាកយ៉ាងតិច៧៧ម៉ោងក្នុង១សប្តាហ៍





## ០៣
### ប្រាក់ឈ្នួលសម្រាប់ការងារបន្ថែមម៉ោង និងការងារក្នុងថ្ងៃឈប់សម្រាក

**ផ្នែកកែច្នៃអាហារសមុទ្រ**

- ការបន្ថែមម៉ោងចំថ្ងៃធ្វើការនិយោជកត្រូវបង់ប្រាក់ក្នុងអត្រាដែលមិនទាបជាង១.៥ដងនៃប្រាក់ឈ្នួលគោល។
- ប្រសិនបើពលករតម្រូវឱ្យធ្វើការចំថ្ងៃឈប់សម្រាក និយោជកត្រូវបង់ប្រាក់ទ្វេរដងនៃប្រាក់ឈ្នួលគោល។

**ផ្នែកនេសាទ**

- ពលករនេសាទមិនត្រូវបានអនុញ្ញាតឱ្យធ្វើការបន្ថែមម៉ោងទេ។

## ០៤
### សុខភាព និង សុវត្ថិភាពការងារ

និយោជកត្រូវដាក់វិធានការ និងផ្តល់សម្ភារការពារសុវត្ថិភាពឱ្យបានគ្រប់គ្រាន់ដល់ពលករដែលធ្វើការងារពាក់ព័ន្ធគ្រឿងម៉ាស៊ីន គ្រឿងអេឡិចត្រូនិចឬធ្វើការងារនៅកន្លែងបិទជិត។



## ០៥
### សម្រាកពេលឈឺ (ដែលមិនបង្កឡើងពីការបំពេញការងារ ឬគ្រោះថ្នាក់ការងារ)



- ពលករមានសិទ្ធិសុំច្បាប់សម្រាកពេលឈឺ។
- ពលករទទួលបានការឈប់ សម្រាកពេលឈឺដោយទទួលបានប្រាក់ឈ្នួលចំនួន៣០ថ្ងៃក្នុង១ឆ្នាំ។
- និយោជកអាចស្នើសុំលិខិតបញ្ជាក់ពីពេទ្យសម្រាប់ការស្នើសុំឈប់សម្រាកឈឺចំនួន៣ថ្ងៃឡើងទៅ។

## ០៦
### សម្រាកមាតុភាព



- ពលករមិនតម្រូវឱ្យធ្វើតេស្តសម្រាប់ការស្នើសុំឈប់សម្រាកមាតុភាពនោះទេ។
- ពលករមិនត្រូវធ្វើកិច្ចការណាដែលបណ្តាលឱ្យឈឺឬលើសកម្លាំងប្រសិនបើពលករកំពុងមានផ្ទៃពោះ។
- ពលករអាចស្នើសុំឈប់សម្រាកមាតុភាពដល់ទៅ៩៨ថ្ងៃ។
- ការឈប់សម្រាកមាតុភាពដោយទទួលបានប្រាក់ឈ្នួលមានចំនួន៤៥ថ្ងៃនៃរយៈពេលសម្រាកមាតុភាពសរុបចំនួន៩៨ថ្ងៃ។
- ពលករមានផ្ទៃពោះមិនតម្រូវឱ្យធ្វើការងារបន្ថែមម៉ោង ឬធ្វើការក្នុងថ្ងៃឈប់សម្រាក និងក្នុងចន្លោះម៉ោង១០យប់ដល់ម៉ោង៦ព្រឹកនោះទេ។
- និយោជកមិនអាចបញ្ចប់កិច្ចសន្យាការងារដោយសារតែពលករមានផ្ទៃពោះនោះទេ។

## ០៧
### ការឈប់សម្រាកប្រចាំឆ្នាំ

**ផ្នែកកែច្នៃអាហារសមុទ្រ**

ប្រសិនបើពលករបំពេញការងារបាន១ឆ្នាំនោះពលករមានសិទ្ធិស្របច្បាប់ទទួលបានការឈប់សម្រាកប្រចាំឆ្នាំចំនួនមិនតិចជាង៦ថ្ងៃ។

**ផ្នែកនេសាទ**

ពលករទទួលបានការឈប់សម្រាកប្រចាំឆ្នាំដោយទទួលបានប្រាក់ឈ្នួលយ៉ាងតិចចំនួន៣០ថ្ងៃជំនួសការឈប់សម្រាកប្រចាំសប្តាហ៍ និងការឈប់សម្រាកបុណ្យប្រពៃណី។ ប្រសិនបើពលករតម្រូវឱ្យធ្វើការចំថ្ងៃឈប់សម្រាកនោះនិយោជកត្រូវផ្តល់ប្រាក់ឈ្នួលទ្វេរដង ។

## ០៨
### ការឈប់សម្រាកបុណ្យប្រពៃណី



**ផ្នែកកែច្នៃអាហារសមុទ្រ**

- ពលករត្រូវទទួលបានប្រាក់ឈ្នួលធម្មតាក្នុងកំឡុងពេលឈប់សម្រាកបុណ្យប្រពៃណី។
- ពលករមានសិទ្ធិឈប់សម្រាកចំនួន១៣ថ្ងៃរួមទាំងទិវាការងារ។
- ពលករមានសិទ្ធិឈប់សម្រាកជំនួសនៅថ្ងៃធ្វើការបន្ទាប់ប្រសិនបើថ្ងៃឈប់សម្រាកបុណ្យប្រពៃណីចំថ្ងៃឈប់សម្រាកចុងសប្តាហ៍។
- ប្រសិនបើពលករតម្រូវឱ្យធ្វើការចំថ្ងៃដែលពលករត្រូវទទួលបានការឈប់សម្រាកជំនួសសម្រាប់បុណ្យប្រពៃណី និយោជកត្រូវបង់ប្រាក់ឈ្នួលយ៉ាងតិចទ្វេដង។

## ០៩
### ប្រាក់បំណាច់ (ប្រាក់សំណងសម្រាប់ការបញ្ចប់កិច្ចសន្យាការងារ)

ពលករត្រូវទទួលបានប្រាក់បំណាច់ប្រសិនបើនិយោជកបណ្តេញពលករចេញពីការងារឬបិទបញ្ចប់អាជីវកម្ម។ ចំនួនប្រាក់បំណាច់ត្រូវផ្អែកតាមរយៈពេលនៃការបំពេញការងារដូចខាងក្រោម៖

- ចំនួន១២០ថ្ងៃប៉ុន្តែតិចជាង១ឆ្នាំ៖ ទទួលបាន៣០ថ្ងៃនៃប្រាក់ឈ្នួលគោល
- ចំនួន១ឆ្នាំប៉ុន្តែតិចជាង៣ឆ្នាំ៖ ទទួលបាន៩០ថ្ងៃនៃប្រាក់ឈ្នួលគោល
- ចំនួន៣ឆ្នាំប៉ុន្តែតិចជាង៦ឆ្នាំ៖ ទទួលបាន១៨០ថ្ងៃនៃប្រាក់ឈ្នួលគោល
- ចំនួន៦ឆ្នាំប៉ុន្តែតិចជាង១០ឆ្នាំ៖ ទទួលបាន២៤០ថ្ងៃនៃប្រាក់ឈ្នួលគោល
- ច្រើនជាង១០ឆ្នាំ៖ ទទួលបាន៣០០ថ្ងៃនៃប្រាក់ឈ្នួលគោល

ពលករត្រូវបំពេញការងារជាប់ៗគ្នាយ៉ាងតិចចំនួន១២០ថ្ងៃដើម្បីមានសិទ្ធិទទួលបានប្រាក់បំណាច់។



SHIP TO SHORE RIGHTS SOUTH EAST ASIA | International Labour Organization | Funded by the European Union

## កម្មវិធីសិទ្ធិពលករនេសាទអាស៊ីអាគ្នេយ៍

លើកកម្ពស់ការធ្វើទេសន្តរប្រវេសន៍ការងារប្រកបដោយសុវត្ថិភាព ប្រកតី និងការងារសមរម្យសម្រាប់ពលករទេសន្តរប្រវេសន៍នៅផ្នែកនេសាទ និងកែច្នៃអាហារសមុទ្រនៅអាស៊ីអាគ្នេយ៍


shiptoshorerights@ilo.org

ការិយាល័យអង្គការអន្តរជាតិខាងការងារប្រចាំតំបន់អាស៊ី និងប៉ាស៊ីហ្វិក
អាគារអង្គការសហប្រជាជាតិ រ៉ាត់ចាដាំណឺនណុក
ក្រុងបាងកក ១០២០០ ប្រទេសថៃ
ទូរស័ព្ទ ៖ +៦៦ ២២៨៨ ១៧៦២
ទូរសារ ៖ +៦៦ ២២៨០ ១៧៣៥
អ៊ីម៉ែល ៖ info@ilo.org
គេហទំព័រ ៖ www.ilo.org


## ១០
## សិទ្ធិចូលរួមជាសមាជិកសហជីព

- ក្នុងនាមជាសមាជិកនៃសហជីព ពលករអាចស្នើនូវតម្រូវការ និងចរចារជាមួយនិយោជកស្តីពីប្រាក់ឈ្នួល អត្ថប្រយោជន៍បន្ថែម និងស្ថានភាពការងារ។
- ពលករទេសន្តរប្រវេសន៍នៅប្រទេសថៃមានសេរីភាពក្នុងការចូលរួមជាសមាជិកសហជីពការងារនៅកន្លែងការងារ ឬនៅក្នុងផ្នែកការងារដូចគ្នា។
- និយោជកមិនមានសិទ្ធិហាមឃាត់ពលករក្នុងការចូលរួមជាសមាជិកសហជីពឡើយ។

### សាមគ្គីភាពនឹងធ្វើឱ្យយើងកាន់តែខ្លាំង!



**ការរួមគ្នាជាធ្លុងមួយ គឺជាជម្រើសដ៏ប្រសើរសម្រាប់កសាងភាពខ្លាំង និងអនុវត្តសិទ្ធិ។**

បណ្ដាញសិទ្ធិពលករនេសាទ
នៅខេត្តស៊ុងខ្លា
លេខទូរស័ព្ទ៖
+៦៦ ៧៤៣១ ៤២៦២

បណ្ដាញសិទ្ធិពលករនេសាទ
នៅខេត្តរ៉ះណង
លេខទូរស័ព្ទ៖
+៦៦ ៧៧៨១ ០២១៧

បណ្ដាញសិទ្ធិពលករនេសាទ
នៅខេត្តត្រាត
លេខទូរស័ព្ទ៖
+៦៦ ៣៩៥១ ៣៥០០

សហព័ន្ធទំនាក់ទំនង
សហគ្រាសពលកររដ្ឋ
លេខទូរស័ព្ទ៖
+៦៦ ២៥៣៧ ៤៩៧៣

## ១១
## ការដាក់ពាក្យបណ្ដឹងរបស់ពលករ

មានមធ្យោបាយជាច្រើនសម្រាប់ជួយពលករពេលមានបញ្ហា៖

- ទាក់ទងមកអង្គការសង្គមស៊ីវិល និងសហជីព
- ទាក់ទងមកការិយាល័យការពារសិទ្ធិការងារ
- ទាក់ទងមកអធិការកិច្ចការងារ



## ១២
## លក្ខខណ្ឌសម្រាប់ការងារក្នុងប្រទេសថៃ



- ពលករត្រូវតែមានអាយុយ៉ាងតិច១៨ឆ្នាំដើម្បីអាចធ្វើការងារលើកប៉ាល់នេសាទបាន។
- ពលករមិនតម្រូវឱ្យបង់ប្រាក់សម្រាប់ការជ្រើសរើសដើម្បីធ្វើការងារនៅប្រទេសថៃឡើយ។
- និយោជកត្រូវផ្ដល់ឱ្យពលករនូវកិច្ចសន្យាការងារជាលាយលក្ខណ៍អក្សរមួយច្បាប់ជាភាសាខ្មែរ។
- ពលករត្រូវតែមានកិច្ចសន្យាការងារមួយច្បាប់ ប្រសិនបើពុំមាននិយោជកត្រូវផ្ដល់ជូនពលករមួយច្បាប់។
- ពលករមានសិទ្ធិទទួលបានអត្ថប្រយោជន៍កិច្ចគាំពារសង្គមឬការធានារ៉ាប់រងឯកជន។
- កូនៗរបស់ពលករមានសិទ្ធិទទួលបានការអប់រំនៅប្រទេសថៃ។ មានអង្គការជាច្រើនដូចជាមូលនិធិសម្រាប់ការអប់រំ និងការអភិវឌ្ឍន៍ ផ្ដល់ការអប់រំដល់កូនៗ និងយុវជននៃពលករទេសន្តរប្រវេសន៍។

## ១៣
## ការរើសអើងត្រូវបានហាមឃាត់

- ពលករមិនត្រូវទទួលបានប្រាក់ឈ្នួលខុសគ្នាដោយសារអត្តសញ្ញាណរបស់ពលករនោះទេ (ជាតិសាសន៍ ជនជាតិ ភេទ ឬនិន្នាការភេទ)។

## # ការស្វែងរកការជួយ

**ក្រសួងការងារប្រទេសថៃ**
ទូរស័ព្ទទាន់ហេតុការណ៍៖ ១៥០៦/១៥៤៦/១៣០០
ទូរស័ព្ទទាន់ហេតុការណ៍សម្រាប់ពលករទេសន្តរប្រវេសន៍៖ ១៦៩៤

**មូលនិធិសម្រាប់ការអប់រំ និងការអភិវឌ្ឍន៍**
ទូរស័ព្ទទាន់ហេតុការណ៍៖+៦៦ ៦២ ៩៧៨ ១០០៩

**មូលនិធិសិទ្ធិមនុស្ស និងអភិវឌ្ឍន៍**
ទូរស័ព្ទ៖+៦៦ ៨៦ ៧៥៦ ០៨៣៥

**បណ្ដាញសិទ្ធិពលករនេសាទ**
(ខេត្តរ៉ះណង ឈុមផន ស៊ុងខ្លា និងត្រាត)
ទូរស័ព្ទ៖+៦៦ ៧៤៣១ ៤២៦២
គេហទំព័រ៖ justiceforfishers.org

**មូលនិធិរ៉ាក់ថៃ (ខេត្តសះមុតសាខន)**
ទូរស័ព្ទ៖+៦៦ ៣៤៨៣ ៤៨២៨

**មជ្ឈមណ្ឌលស្តេឡាម៉ារីសស៊ីហ្វៀរី**
ទូរស័ព្ទ៖+៦៦ ៨១ ៤០១ ២៨១៦

**សហព័ន្ធទំនាក់ទំនងសហគ្រាសពលកររដ្ឋ**
ទូរស័ព្ទ៖+៦៦ ៨៦ ៧៥២ ៨៥៩៣

SHIP TO SHORE RIGHTS SOUTH EAST ASIA | International Labour Organization | Funded by the European Union

# សិទ្ធិការងារក្នុងផ្នែកនេសាទ និងកែច្នៃអាហារសមុទ្រ



shiptoshorerights.org


គម្រោងទទួលបានមូលនិធិពីសហភាពអឺរ៉ុប
អត្ថន័យទាំងអស់នៅក្នុងការបោះពុម្ពផ្សាយនេះមិនបានឆ្លុះបញ្ចាំងពីទស្សនរបស់សហភាពអឺរ៉ុបនោះទេ។